# ជីវប្រវត្តរបស់ អ៊ីម៉ាំ អាល់-អាស់ការី صلوات الله عليه والسلام



សៃយីដ្ ម៉ាស់ូឌី អាយ៉ាទុលឡ៏ហ៊ី

ស្ហាគីប បេនបេឌីរ៉ា




## អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام

*-ព្រះនាម ៖ អាល់–ហ្ហាសាន់ ។*

*-ព្រះនាមចំតើត ៖ អាល់–អ៊ាស់ការី ។*

*-ព្រះគារវនាម ៖ អាប៊ូ មូហ្ហាំម៉ាដ់ ។*

*-ព្រះនាមព្រះបិតា ៖ អ៊ីម៉ាំអ៊ាលី អាល់–ហាឌី صلوات الله عليه والسلام ។*

*-ថ្ងៃប្រសូត ៖ ថ្ងៃទី ៨ ខែរ៉ប៊ីអ៊ុល់ អាស្សានី ឆ្នាំ ២៣២ សកករាជហ៊ិជ្ជរ៉ោះត្ត៍ ។*

*-ថ្ងៃទទួលទុក្ករកម្ម ៖ ថ្ងៃទី ៨ ខែរ៉ប៊ីអ៊ុល់ អាវ៉ាល់ ឆ្នាំ ២៦០ សកករាជហ៊ិជ្ជរ៉ោះត្ត៍ ។*

*-កន្លែងតម្កល់ព្រះចេតិយ ៖ សាម៉ារ៉អ៊ុំ ប្រទេសអ៊ីរ៉ាក្ក ។*

ٱلْحَمْدُ لِلَّهِ رَبِّ ٱلْعَٰلَمِينَ

19/08/2016



# បញ្ជីមាតិកា

កំណើត....4
ការមើលរបស់សត្រូវមកលើអ៊ីម៉ាំ صلوات الله عليه والسلام....6
ប្រឈមនឹងអចិរភាពនយោបាយ....8
អ៊ីម៉ាំ صلوات الله عليه والسلام នៅក្រោមការកៀបសង្កត់....11
សកម្មភាពវិទ្យាសាស្ត្ររបស់អ៊ីម៉ាំ صلوات الله عليه والسلام....14
ប្រឆាំងពួកបោកប្រាស់....15
មេរៀនកែតម្រង់....18
ប្រឈមមុខនឹងទស្សនវិទូនៃប្រទេសអ៊ីរ៉ាក់....22
ការលោមចិត្តនិងប្រផ្នូលល្អ....25
ទុក្ករកម្មរបស់អ៊ីម៉ាំ صلوات الله عليه والسلام....26
សម្រង់ព្រះវចនៈត្រចះត្រចង់....29
អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام....31

# កំណើត

*អ៊ីម៉ាំហ្សាសាន់ صلوات الله عليه والسلام រាជបុត្ររបស់អ៊ីម៉ាំអាល់–ហាឌី صلوات الله عليه والسلام ជាអ៊ីម៉ាំអាស់លុល–បៃត៍ عليهم السلام ទី ១១ ។ ព្រះអង្គប្រសូតថ្ងៃទី ៨ ខែរ៉ប៊ីអ៊ុ អាស្សានី ឆ្នាំ ២៣២ សករាជហ៊ិជ្រ៉ោះត្ទ័ ។ ព្រះអង្គបានរស់នៅជាមួយព្រះបិតាព្រះអង្គ ២២ ឆ្នាំ ។*

*បន្ទាប់ពីអ៊ីម៉ាំអាល់–ហាឌី صلوات الله عليه والسلام បានទទួលទុក្ករកម្មក្នុងឆ្នាំ ២៥៤ សករាជហ៊ិជ្រ៉ោះត្ទ័ អ៊ីម៉ាំហ្សាសាន់ រាជបុត្រព្រះអង្គ បានទទួលបន្ទុកអ៊ីម៉ាម៉ាស្ទ៍ ។ ព្រះអង្គទទួលទុក្ករកម្មបន្ទាប់ពីបានដឹកនាំសហគមន៍មុស្លីមអស់រយៈពេល ៦ ឆ្នាំ ។ មាតារបស់អ៊ីម៉ាំអាល់–អ៊ាស់ការី صلوات الله عليه والسلام មាននាមថា សៅសាន ជានារីមានសីលធម៌ខ្ពង់ខ្ពស់ មានសន្តានចិត្តជ្រះថ្លាបរិសុទ្ធស័ក្តិសមជារាជមាតារបស់ព្រះទទ្សការីរបស់អល់ឡោះហ៍ عزّ وجلّ នៅលើផែនដី ។*

*អ៊ីម៉ាំទី ១១ បានប្រសូតនៅឯនគរម៉ាឌីណាស្ទ៍ ។ ព្រះអង្គបានរស់នៅឯនគរនេះកាលពីក្មេងវ័យ ពេលស្តេចខ៏លិហ្វអាល់–មូតាវ៉ាក់គីលបានកោះហៅព្រះបិតាព្រះអង្គទៅឯនគរសាម៉ារ៉អ៊ុ ព្រះអង្គបានទៅតាម បានរស់នៅឯរាជធានីសាម៉ារ៉អ៊ុក្នុងសភាពដែលយើងបានអធិប្បាយរួចហើយ នៅក្នុងជីវប្រវត្តិរបស់អ៊ីម៉ាំអាល់–ហាឌី صلوات الله عليه والسلام ។*



*ងាយស្រួល ។*

# សម្រង់ព្រះវចនៈត្រចះត្រចង់

*– បុគ្គលមានអំណាចដែលលះបង់សច្ចធម៌នឹងត្រូវបាក់មុខ ។ បុគ្គលបាក់មុខដែលកាន់សច្ចៈធម៌ជាប់នឹងក្លាយទៅជាបុគ្គលមានអំណាច ។*

*– សម្រាប់អល់ឡោះហ៍ عزّ وجلّ គុណសម្បត្តិពីរដែលមិនមានអ្វីប្រសើរជាងនោះគឺជឿអល់ឡោះហ៍ عزّ وجلّ និងផ្តល់ផលប្រយោជន៍ដល់បងប្អូនរួមជំនឿ ។*

*– ក្មេងណាព្រហើនដាក់ឪពុកកាលពីនៅក្មេងវ័យ នឹងរមិលគុណពេលពេញវ័យ ។*

*– សម្តែងសេចក្តីរីករាយចំពោះអ្នកមានទុក្ខ មិនមែនជាសេចក្តីគួរសមទេ ។*

*– បាបធម៌ត្រូវឃាំងទុកក្នុងទ្រូងដែលមានមុសាវាទជាសោ ។*

صلوات الله عليه والسلام ត្រូវបញ្ចុះក្បែរព្រះបិតាព្រះអង្គ នៅឯសាម៉ារ៉អ៊ុ ។ ព្រះចេតិយព្រះអង្គនៅរហូតដល់សព្វថ្ងៃ ជាស្ថានទីទស្សនៈផ្ដើមមួយ ។

មុននឹងបានឆ្លើយតបការកោះហៅទៅកាន់សុគតិភព អ៊ីម៉ាំអាល់-អ៊ុាស់ការី صلوات الله عليه والسلام បានបំពេញបេសកកម្មចុងក្រោយបង្អស់របស់ព្រះអង្គ បានយ៉ាងស្រេចបាច់គឺៈ លាក់ព្រះរាជបុត្រព្រះអង្គក្នុងកន្លែងដែលប្រកបដោយសុវត្ថិភាព គឺអាល់-ម៉ាស់ឌី صلوات الله عليه والسلام ដែលបណ្ដាអ្នកស្រឡាញ់អាស់លុល-បៃត៍ عليهم السلام រង់ចាំយ៉ាងអន្ទះអន្ទែង ។ ទោះជាអាជ្ញាធរអ៊ុាប់បាស់បានឆែកឆេរ ទោះជាបានត្រួតពិនិត្យមហេសីទាំងអស់របស់អ៊ីម៉ាំ អាល់-អ៊ុាស់ការី صلوات الله عليه والسلام ដើម្បីសម្លាប់ទារកប្រុសទាំងអស់ដែលទើបនឹងប្រសូតមកក៏ដោយ អ៊ីម៉ាំអាល់-អ៊ុាស់ការី صلوات الله عليه والسلام បានបន្សល់ទុកនូវព្រះទាយាទព្រះអង្គដែលមានព្រះជន្មាយុ ៥ វស្សាដើម្បីបំពេញបេសកកម្មសំខាន់បំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិគឺៈ ដាក់ច្បាប់អល់ឡោះហ៊្វ عزوجل ឲ្យប្រតិបត្តិតាម និងបង្កើតសង្គមសាកលដែលប្រកបដោយសមធម៌ ។

សូមសិរីសួស្តីកើតមានដល់អ៊ីម៉ាំអាល់-អ៊ុាស់ការី صلوات الله عليه والسلام ។ សូមអល់ឡោះហ៊្វ عزوجل ឲ្យព្រះទាយាទព្រះអង្គ អាល់-ម៉ាស់ឌី صلوات الله عليه والسلام លេចឡើងយ៉ាង



ទំនៀមទំលាប់អ៊ីមស្លាមតម្រូវឲ្យហៅអ៊ីម៉ាំហ្វាសាន់ អាល់-អ៊ុាស់ការី صلوات الله عليه والسلام ដោយសេចក្ដីគោរព តាមតម្រុយឈ្មោះរបស់កូនច្បងគេរបស់ព្រះអង្គគឺៈ មូហ្វាំម៉ាដ្ឌ ដែលពុំមែនជាអ្នកណាក្រៅពីអ៊ីម៉ាំអាស់លុល-បៃត៍ទី ១២ នោះទេ ហើយដែលជាអ្នករំដោះមនុស្សជាតិ ។

អ៊ីម៉ាំមានព្រះនាមចំតើតច្រើន តែព្រះនាមល្បីជាងគេគឺ អាល់-អ៊ុាស់ការី មានន័យថា អ្នកស្នាក់នៅឯអ៊ុាស់ការ ស្ថានទីមួយនៅឯស្រុកសាម៉ារ៉អ៊ុ ។

ផែនការក្បត់នៅក្នុងរាជវាំងអ៊ុាប់បាស់មិនបានប្រណីដល់ជីវិត របស់ស្ដេចខ៏លិហ្វអាល់-មូអ៊ុាតាស់ (المعتز) ទេ ស្ដេចខ៏លិហ្វរូបនេះត្រូវពួកទួរគីសម្លាប់ដើម្បីតែងតាំងអាល់-មុះហ៊្វតាឌី (المهتدي) ជាខ៏លិហ្វជំនួស អាល់-មុះហ៊្វតាឌី ក៏បានស្គាល់វាសនាអាក្រក់នេះដែរ ។ នៅទីបំផុតអំណាចបានធ្លាក់ក្នុងដៃអាល់-មុអ៊ុំតាម៉ាដ្ឌ (المعتمد) ។ ព្រោះតែខ្លាចទទួលរងវាសនាតែមួយនេះដែរ អាល់-មុអ៊ុំតាម៉ាដ្ឌបានមកជួបអ៊ីម៉ាំ صلوات الله عليه والسلام សូមឲ្យព្រះអង្គជួយបួងសួងអល់ឡោះហ៊្វ عزوجل សូមព្រះអង្គឲ្យខ្លួនមានអាយុជីវិតយឺនយូរ ។ រឿងនេះអាចធ្វើឲ្យលោកអ្នកអានប៉ះទង្គិចចិត្តខ្លាំង ។ មែនហើយ ប្រហែលជាពិបាកយល់ដែលអ៊ីម៉ាំអាចជួយធ្វើឲ្យសេចក្ដីប្រថ្នារបស់បុគ្គលសាហាវយង់ឃ្នង លួចប្លន់

អំណាចនោះបានសម្រេចដូចបំណង ។ តែចូររំលឹកឡើងវិញថាចាប់តាំងពីសោកនាដកម្មការបាឡាអ៊ុំមក អល់ឡោះហ៊ូ عزّ وجلّ បានតម្រូវឲ្យអ៊ីម៉ាំអាស្ស៊ូលុល–បៃត៏ عليهم السلام ទុកឲ្យពួកមុស្លីមទទួលខុសត្រូវលើខ្លួនឯង ពេញទី ឲ្យអ៊ីម៉ាំអាស្ស៊ូលុល–បៃត៏ عليهم السلام មានតែតួនាទីជាអ្នកអប់រំ ជាអ្នកបង្ហាត់បង្រៀននិងជាអ្នកចង្អុលបង្ហាញផ្លូវប៉ុណ្ណោះ មិនឲ្យលូកដៃចូលក្នុងការប្រយុទ្ធដណ្តើមអំណាចទេ ។ ដូច្នេះឯងបានជាអាល់–មុអ្ទ់តាម៉ាដ់មានសំណាងបានសោយរាជ្យយ៉ាងយូរ ដោយសារការបួងសួងរបស់ព្រះទឡ្ហការីរបស់អល់ឡោះហ៊ូ عزّ وجلّ នៅលើផែនដី ។ ក្នុងសម័យដែលគ្មានជិរភាពនយោបាយឡើយនោះ ស្តេចខ៏លិហ្វរូបនេះបានកាន់អំណាចអស់រយៈពេលប្រមាណម្ភៃឆ្នាំ ។

អ៊ីម៉ាំបង្ហាញយើងនូវការពិតមួយដែលអាចភ្លេចបានយ៉ាងងាយគឺៈ ជីវិតលោកនេះមិនមានតម្លៃទេសម្រាប់អល់ឡោះហ៊ូ عزّ وجلّ ដូច្នេះឯងបានជាជីវិតលោកនេះងាយស្រួលទៅដល់ សម្រាប់បុគ្គលទាំងឡាយណាដែលឃ្លាតឆ្ងាយជាងគេពីអល់ឡោះហ៊ូ عزّ وجلّ ។

## ការមើលរបស់សត្រូវមកលើអ៊ីម៉ាំ صلوات الله عليه والسلام





ពោរពេញដោយអំពើខុសឆ្គងនិងអយុត្តិធម៌ ។ ដូច្នេះ ស្នេហ៍អើយ អាប៊ូ អាល់-ហ៊ូសែន៍អើយ ចូរអត់ធ្មត់ ។ ផែនដីជារបស់អល់ឡោះហ្ទ់ عز وجل ព្រះអង្គ عز وجل ប្រទានវាឲ្យទៅអ្នកណាដែលព្រះអង្គ عز وجل ជ្រើសរើស ក្នុងចំណោមបាវទាំងឡាយរបស់ព្រះអង្គ عز وجل ។ ជ័យជំនះនឹងបានលើបណ្ដាអ្នកមានសទ្ធាស៊ប់ចិត្ត ។ សូមឲ្យសិរីសួស្ដីកើតមានដល់លោកនិងបក្សពួកយើង សូមឲ្យព្រះធម៌មេត្តានិងព្រះពរអល់ឡោះហ្ទ់ عز وجل មានដល់អស់លោក សូមឲ្យអល់ឡោះហ្ទ់ عز وجل ប្រទានពរជ័យសិរីសួស្ដី ដល់មូហ្ចាំម៉ាដ្ឋនិងរាជបុត្ររាជនត្តារបស់មូហ្ចាំម៉ាដ្ឋ ។»

## ទុក្ករកម្មរបស់អ៊ីម៉ាំ صلوات الله عليه والسلام

តាំងពីព្រះអង្គមានព្រះជន្មាយុ ៥ វស្សាម៉្លេះ កាលព្រះអង្គត្រូវកោះហៅជាមួយព្រះបិតាព្រះអង្គ ទៅកាន់នគរសោម៉ារ៉អ៊ុ អ៊ីម៉ាំអាល់-អ៊ាស់ការី صلوات الله عليه والسلام បានរស់នៅក្រោមការកៀបសង្កត់យ៉ាងតឹងរ៉ឹង ក្នុងពន្ធនាគារដែលយ៉ាប់យ៉ឺនបំផុត លុះអល់ឡោះហ្ទ់ عز وجل បានអនុញ្ញាតឲ្យព្រះអង្គឡើងទៅកាន់សុគតិភព ថ្ងៃទី ៨ ខែរ៉ប៊ីអ៊ុ អាវ៉ាល់ ឆ្នាំ ២៦០ សករាជហ៊ិជ្រ៉ោះត្ន៍ បន្ទាប់ពីត្រូវថ្នាំបំពុលក្រោមបញ្ជាការរបស់ស្ដេចខ៏លិហ្វ ។ ព្រះរាជសពរបស់អ៊ីម៉ាំអាល់-អ៊ាស់ការី





អាស្ម៉ាដ់ ប៊ិន ខ៏គន់ (أحمد بن خاقان) សហការីជំនិតរបស់សន្តតិវង្ស អាប់បាស់បានបន្សល់ទុកឲ្យយើងនូវសាក្សីមួយ ដែលឆ្លុះបញ្ចាំងឲ្យឃើញកេរ្តិ៍ឈ្មោះរបស់អ៊ីមុាំអាល់–អាស់ការី صلوات الله عليه والسلام ។ លោកបានធ្វើសេចក្តីរាយការណ៍ថាៈ «ពេញមួយស្រុកសាម៉ារ៉ា ក្នុងចំណោមកូនចៅទាំងអស់របស់អាលី صلوات الله عليه والسلام ប៊ិន អាប៊ូ តូលិប رضي الله عنه ខ្ញុំមិនដែលឃើញបុរសណាស្មើហាសាន់ ប៊ិន អាលី ប៊ិន មូហាំម៉ាដ់ ប៊ិន អាលី–អារីដ្ឋ៍ صلوات الله عليه والسلام ទេ ។ ខ្ញុំមិនដែលឃើញអ្នកណាមួយមានសីលធម៌ ដែលអាចប្រៀបបាននឹងសីលធម៌ព្រះអង្គទេ គឺៈ សេចក្តីអាណិតអាសូរ, គតិបណ្ឌិត, យុត្តិធម៌, សេចក្តីថ្លៃថ្នូរនិងចិត្តបុណ្យ ។ អាប់ឌុលឡោះហ្ម ឪពុករបស់អាស្ម៉ាដ់ ប៊ិន ខ៏គន់ បានបន្ថែមដែរថា បើអំណាចរបូតពីសន្តតិវង្សអាប់បាស់ មិនមានអ្នកណាមួយដែលសក្តិសមនឹងអំណាចនោះជាងអ៊ីមុាំអាស់ការី صلوات الله عليه والسلام ទេ ។ យ៉ាងហោចណាស់ព្រះអង្គមានសីលធម៌ខ្ពង់ខ្ពស់និងមានសមត្ថភាពជាងគេ ។

## ប្រឈមនឹងអចិរភាពនយោបាយ

ប្រជារាស្ត្រមុស្លីមគាន់តែពិបាកទ្រាំមើល ពួកទួរគីរឹបយកអំណាចនៅឯរាជវាំងអាប់បាស់ ។ ការបះបោរគាន់តែកើតមានឡើងជាញឹកញយ ។ ប្រជា



ហើយសម្មតិកម្មរបស់លោកដែលថាគួរអានមានបដិវាទកម្មនោះ ត្រូវដួលរលំ ។ នៅទីបំផុតលោកបានចោលគម្រោងការលោក ហើយបានដុតសន្លឹកសំណេរអត្ថបទដែលលោកបានសរសេរហើយនោះចោល ។

## ការលោមចិត្តនិងប្រផ្នូលល្អ

អ៊ីមុាំអាល់–អាស់ការី صلوات الله عليه والسلام ដឹងច្បាស់ថាបណ្តាសាវក និងអ្នកស្រឡាញ់ព្រះអង្គរស់ក្នុងស្ថានភាពណា ហើយពួកគេរង់ចាំថ្ងៃដែលពួកគេអាចបញ្ចេញឲ្យឃើញជំនឿរបស់ខ្លួន និងប្រតិបត្តិការកសាងសង្គមល្អនិងត្រឹមត្រូវដោយសេរី ។ នៅក្នុងសំបុត្រលោមចិត្តនិងដាស់តឿនឲ្យមានការអត់ធ្មត់និងមានសេចក្តីមាំមួន ដែលព្រះអង្គបានសរសេរទៅសាវកភក្តីឯកម្នាក់របស់ព្រះអង្គ ឈ្មោះ អាលី ប៊ិន អាល់–ហ៊ូសែន ប៊ិន បាបាវ៉ៃហ្ម អាល់–គូមី (علي بن الحسين بن بابويه القمي) ថាៈ «ចូរអត់ធ្មត់ រង់ចាំមហាជោគជ័យ ។ ព្រះសាស្តា صلى الله عليه وآله وسلم មានព្រះវចនៈថាៈ “អំពើល្អបំផុតរបស់សហគមន៍ខ្ញុំគឺការរង់ចាំមហាជោគជ័យ (ការផុតចាកទុក្ខ) ។” អ្នកតាមយើងរស់នៅក្នុងសេចក្តីព្រួយលុះដល់ថ្ងៃដែលបុត្រខ្ញុំលេចឡើង ដូចព្រះសាស្តា صلى الله عليه وآله وسلم បានគ្រោងទុកជាមុនហើយ ។ គេនឹងធ្វើឲ្យផែនដីពោរពេញដោយយុត្តិធម៌ ដូចកាលវាបាន





រាស្ត្រមុស្លីមកាន់តែគាំទ្រការបះបោរឡើងដោយពេញចិត្ត ។

សម័យអ៊ីម៉ាំអាល់–អ៊ាស់ការី បណ្តាកូនចៅច្រើននាក់របស់អ៊ាលី صلوات الله عليه والسلام ប៊ិន អាប៊ូ តឺលិប رضي الله عنه ដែលគេហៅថាអ៊ាឡាវី និងអ្នកផ្សេងព្រេងច្រើននាក់ដែលអះអាងខ្លួនជាអ្នកអ៊ាឡាវីនោះ បានរើបម្រះហើយបានបង្កើតរដ្ឋស្វយ័តដែលមានថេរភាពមិនយូរមិនឆាប់ ។ ក្នុងចំណោមអ្នកបះបោរនេះមាន ហ៊ាសាន់ ប៊ិន ស៊ៃដ៍ អាល់–អ៊ាឡាវី អ្នកតំបន់តឺបារិសតាន (طبرستان ខាងជើងប្រទេសអ៊ីរ៉ង់) ។

តែការវាយប្រហារយ៉ាងខ្លាំងជាងគេទៅលើអាផ្វាធអ៊ាប់បាស់នោះ គឺការបះបោររបស់ពួកស្បែកខ្មៅនៃតំបន់បាស្វ៉ារ៉ោះត៍ ដែលបានបង្កើតរដ្ឋស្វយ័តនៅក្នុងតំបន់នេះ ព្រមទាំងបានប្រព្រឹត្តការកាប់សម្លាប់និងអំពើឃោរឃៅដែលពុំមានមុស្លីមស្មោះត្រង់រូបណាមួយ អាចលើកលែងទោសឲ្យបានឡើយ ។

អ្វីដែលគួរឲ្យអាម៉ាស់នោះគឺ មេដឹកនាំការបះបោរនេះបានអះអាងថាខ្លួនជាអ្នកអ៊ាឡាវី (អ្នកគាំទ្រអ៊ាលី صلوات الله عليه والسلام) អាចធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ព្រះរាជវង្សពិសិដ្ឋនេះ ដែលធ្លាប់តែបានរើបម្រះរកសេរីភាពដោយ





នៅក្នុងព្រះមហាគម្ពីរគួរអាន ។

លោកបានចងក្រងនូវសាត្រាមួយច្បាប់ស្ដីអំពីរឿងនេះ ។ សិស្សម្នាក់របស់ អាល់-កាន់ឌី បាននាំរឿងនេះមកថ្លែងប្រាប់អ៊ីម៉ាំ អាល់-អ៊ាស់ការី صلوات الله عليه والسلام បានសូមព្រះអង្គថា៖ «មិនមានអ្នកណាម្នាក់ក្នុងចំណោមអស់លោកទេ ដែលចាស់គំនិតអាចឃាត់គ្រូរបស់អស់លោក កុំឲ្យគិតគូរអំពីរឿងគួរអាន ?» សិស្សរបស់ទស្សនវិទូបានប្រាប់អ៊ីម៉ាំថា គាត់មិនហ៊ាននិយាយជំទាស់គ្រូគាត់ទេ ។ អ៊ីម៉ាំបានប្រាប់គាត់ថា៖ «ចូរលោកប្រាប់គ្រូលោកថា លោកចង់សួរគ្រូលោកថា៖ “ពេលគេសូត្រគួរអាន តើអ្នកនោះអាចយល់ន័យគួរអានផ្សេងពីន័យដែលលោកគ្រូយល់ទេ ។” គ្រូលោកនឹងឆ្លើយថាអាចដូច្នោះបាន ព្រោះគ្រូលោកជាមនុស្សដែលយល់ពេលលោកឮ ។ ពេលណាគ្រូលោកព្រមទទួលសម្មតិកម្ម (ការសន្មត, ការស្មាន) ហើយ ចូរលោកប្រាប់គ្រូលោកថា៖ “លោកគ្រូអាចដឹងបានដូចម្ដេចទៅ ថាអ្នកនោះអាចយល់ន័យខុសពីន័យដែលលោកគ្រូយល់ ? លោកគ្រូអាចយល់ន័យខុសពីអ្នកនោះ ។”» សិស្សបានត្រឡប់ទៅជួបគ្រូវិញ បានសួរគ្រូដោយសំណួរដែលអ៊ីម៉ាំបានប្រាប់នោះ ។ អាល់-កាន់ឌីបានទទួលស្គាល់ថាគួរអានអាចមានអត្ថន័យច្រើន

ឲ្យគាត់អង្គុយជិត ។ អាប៊ូ អាល់-ហ៊ាសាន់ ឆ្ងល់ណាស់ ក៏បានសួរប៊ិន អ៊ីសហ៊ាក់រកមូលហេតុដែលធ្វើឲ្យលោកផ្លាស់ប្តូរឥរិយាបថបែបនេះ ។ បុរសតំណាងអ៊ីម៉ាំអាល់-អ៊ាស់ការីបានតំណាលរឿងលោក ជាមួយព្រះទឡ្ហការីរបស់អល់ឡោះហ៊ូ عزّ وجل នៅលើផែនដី ។ រឿងនេះបានធ្វើឲ្យបុរសអ៊ាឡាវីរំភើបណាស់ ហើយបានភ្ញាក់រលឹក សម្រេចចិត្តលែងប្រព្រឹត្តកំហុសតទៅទៀត ។ លុះមកដល់ផ្ទះវិញ គាត់បានវាយកម្ទេចគ្រឿងប្រើប្រាស់និងភាជនៈសម្រាប់ដាក់គ្រឿងស្រវឹងចោលអស់ ។ ចាប់តាំងពីថ្ងៃនោះតទៅ គាត់សង្វាតតែគោរពសក្ការៈអល់ឡោះហ៊ូ عزّ وجل ទេ ។

## ប្រឈមមុខនឹងទស្សនវិទូនៃប្រទេសអ៊ីរ៉ាក់

គេចាត់ទុកអ៊ីសហ៊ាក់ អាល់-កាន់ឌី (إسحاق الكندي) ជាទស្សនវិទូមួយរូបរបស់ពួកអារ៉ាប់ ។ ដើម្បីស្គាល់ស័ក្តិយសរបស់លោកក្នុងវិស័យវិទ្យាសាស្ត្រ យើងសូមរំលឹកឡើងវិញថាលោកជាគ្រូរបស់អាល់-ហ្វារ៉ាប៊ី ។

ស្រង់យកចំណេះវិជ្ជាមកពីព្រភពផ្សេង ពីវិទ្យាស្ថានអាស់លុល-បៃត៍ عليهم السلام ទស្សនវិទូរូបនេះបានទាល់គំនិតក្នុងពេលសូត្រគួរអាន ។ បន្ទាប់ពីបានជញ្ជឹងគិតយ៉ាងយូរ លោកក៏បានយល់ឃើញថាមានបដិវាទកម្ម (ភាពផ្ទុយគ្នា)



គោរពវិន័យសាសនាអ៊ីស្លាមនិងសេចក្តីថ្លៃថ្នូររបស់មូស្លីមទាំងពួង ។ អ៊ីម៉ាំអាល់-អ៊ាស់ការី បានប្រកាសថ្កោលទោសការកាប់សម្លាប់នៅតំបន់បាស្ហ៉េះត្ញ់ ហើយបានប្រកាសថាបុគ្គលដែលដៃដល់ក្នុងបទឧក្រិដ្ឋនេះមិនអាចជាបក្សពួកព្រះអង្គជាដាច់ខាត ។

## អ៊ីម៉ាំ صلوات الله عليه والسلام នៅក្រោមការកៀបសង្កត់

ទោះជានៅឆ្ងាយពីអំណាចក៏ដោយ អ៊ីម៉ាំអាល់-អ៊ាស់ការីត្រូវគេឃុំឃាំងក្រោមបញ្ជារបស់ស្តេចខ៏លិហ្វ ដោយមានឆ្មាំពន្ធនាគារពីរនាក់ដែលត្រូវជ្រើសរើសក្នុងចំណោមពួកទាហានស៊ីឈ្នួលអមនុស្សធម៌បំផុត ។

ពួកភ្នាក់ងាររបស់ស្តេចខ៏លិហ្វភ្ញាក់ផ្អើលខ្លាំង ពេលបានកត់សម្គាល់ការផ្លាស់ប្តូរឥរិយាបថនិងសីលធម៌របស់ឆ្មាំពន្ធនាគារទាំងពីរនាក់នេះ ដែលនៅក្រោមឥទ្ធិពលបុគ្គលជាប់ឃុំឃាំង ។ បុរសទាំងពីរនាក់បានស្មារលាកំហុស ហើយបានកែខ្លួនទៅជាអ្នកមានជំនឿស៊ប់ចិត្តវិញ ។

ដូចព្រះបិតាព្រះអង្គដែរ អ៊ីម៉ាំអាល់-អ៊ាស់ការីបានប្រឈមនឹងសត្វសាហាវ ។ ប្រវត្តិសាស្ត្របានតំណាលថាស្តេចខ៏លិហ្វសម័យនោះបានបញ្ជាឲ្យដាក់ព្រះអង្គក្នុងលានសត្វសាហាវ ។ តែគួរឲ្យភ្ញាក់ផ្អើលណាស់ សត្វ

សាហាវទាំងនោះទទួលអ៊ីម៉ាំសម័យកាល ព្រះទឡ្ហការីរបស់អល់ឡោះហ៍ عزّ وجلّ នៅលើផែនដី ដូចក្តែស្កួតទទួលម្ចាស់វាអញ្ចឹងដែរ ។

នៅចំពោះមុខអំពើសាហាវយង់ឃ្នងនេះ អ៊ីម៉ាំអាល់–អុាស់ការីមិនលាក់លៀបការប្រទូសប្រឆាំងទៅលើការសង្កន់សង្កិននេះទេ ។ ព្រះអង្គបានដាស់តឿនអ្នកស្រឡាញ់ព្រះអង្គ ឲ្យច្រានចោលអយុត្តិធម៌និងការរំលោបបំពាន ។ ព្រះអង្គបានផ្តាំផ្ញើបណ្តាសាវកព្រះអង្គកុំឲ្យគាត់ផ្តាច់ពីយុត្តិធម៌ ពីការប្រព្រឹត្តិល្អនិងពីការគិតដល់អ្នកដទៃជាដាច់ខាត ។ ដូច្នេះ បណ្តាសាវករបស់អ៊ីម៉ាំអាល់–អុាស់ការីជាសតិសម្បជញ្ញៈរស់រវើករបស់សហគមន៍មុស្លីម ។

អត្តិភាពរបស់អ៊ីម៉ាំអាល់–អុាស់ការីជាភ័ស្តុតាងរស់រវើក និងអចិន្ត្រៃយ៍នៃទ្រឹស្តីពិតរបស់សាសនាអ៊ីស្លាម ។ បុគ្គលគ្រប់រូបដែលមានចិត្តថ្លើមបរិសុទ្ធដែលជួបអ៊ីម៉ាំសម័យកាល បុគ្គលនោះនឹងបានស្គាល់សច្ចធម៌និងបាននៅក្នុងផ្លូវជនភាគតិចត្រឹមត្រូវ ។

ប្រវត្តិសាស្ត្របានលើកឡើងនូវព្រឹត្តិការណ៍មួយ ស្តីអំពីចៅអធិការសាសនាគ្រិស្តដែលបានទទួលការស្រោចស្រង់ បន្ទាប់ពីបានជួបអ៊ីម៉ាំអាល់–អុាស់ការី ។ គេបានសួរលោកថាហេតុអ្វីលោកប្តូរសាសនាមកកាន់





អ្នកប្រមឹក ។ អាស៊ុម៉ាដ៉ូ ប៊ិន អ៊ីសហ្វាក់ អ្នកតំណាងអ៊ីម៉ាំអាល់–អ៊ុាស់ការី ស្របច្បាប់នៅឯស្រុកគុ្ម ជាអ្នកមានសទ្ធាស៊ីប់ចិត្តដែលគេចបុគ្គលអាស្រូវ កេរ្តិ៍ទាំងឡាយ ។ ថ្ងៃមួយ លោកមិនព្រមទទួលអាប៊ូ អាល់–ហ្វាសាន់ ដោយសារតែចរិយាគាត់ បណ្ដាលឲ្យគាត់សៅហ្មងខ្លាំង ។ ពេលវេលាបាន កន្លងផុតទៅ ប៊ិន អ៊ីសហ្វាក់បានទៅបំពេញពិធីហ្វាជ្ជ ចង់កាត់តាមដំណាក់ អ៊ីម៉ាំដើម្បីគំនាប់ព្រះអង្គនិងសូមពរព្រះអង្គ ។ តែលោកបានភ្ញាក់ផ្អើលខ្លាំង ព្រោះអ៊ីម៉ាំមិនព្រមទទួលលោកទេ ។ លោកបាននៅចាំឯមាត់ទ្វារព្រះអង្គ អស់ច្រើនថ្ងៃ លោកសុខចិត្តស្លាប់ជាជាងត្រូវអ៊ីម៉ាំបោះបង់ចោល ។ នៅទី បំផុតអ៊ីម៉ាំបានអនុញ្ញាតឲ្យលោកចូលជួប ហើយបានស្ដីបន្ទោសលោកដែល លោកបានប្រព្រឹត្តចំពោះ អាប៊ូ អាល់–ហ្វាសាន់នោះ ដោយរំលឹកថាការហៅ ទៅរកអល់ទ្បោះហ៊ូ عز وجل មិនមានន័យឡើយថា ប្រឈមនឹងអ្នកដទៃដោយ បំផ្លាញបុគ្គលិកលក្ខណៈរបស់ពួកគេនោះទេ ។ ប៊ិន អ៊ីសហ្វាក់យល់មេរៀន ។ ពេលលោកបានត្រឡប់មកឯស្រុកគុ្មវិញ លោកបានសម្រេចចិត្តទូទាត់អំពើ អាក្រក់ដែលលោកបានធ្វើចំពោះ អាប៊ូ អាល់–ហ្វាសាន់ ។ លុះអាប៊ូ អាល់–ហ្វាសាន់មករកលោកភ្លាម លោកទទួលរាក់ទាក់គាត់ភ្លាម ហើយបាន





សាសនាអ៊ីមស្លាមវិញ ។ លោកបានតបថាអ៊ីម៉ាំអាល់–អ្មាស់ការី صلوات الله عليه والسلام មានបុគ្គលិកលក្ខណៈនិងសីលធម៌របស់ព្រះយេស៊ូ ។ ហើយនេះគ្រប់គ្រាន់ណាស់សម្រាប់បុគ្គលណាដែលស្វែងរកសច្ចៈធម៌ ។

## សកម្មភាពវិទ្យាសាស្ត្ររបស់អ៊ីម៉ាំ صلوات الله عليه والسلام

អ៊ីម៉ាំអាល់–អ្មាស់ការី صلوات الله عليه والسلام ជាអ៊ីម៉ាំអាស់លុល–បៃត៍ عليهم السلام ចុងក្រោយបង្អស់ដែលមានតួនាទីបង្ហាត់បង្រៀនវិទ្យាសាស្ត្រជាសាធារណៈ ។ សម័យអ៊ីម៉ាំអាល់–អ្មាស់ការី صلوات الله عليه والسلام ការអប់រំវិស័យវិទ្យាសាស្ត្រក្នុងសាសនាកំពុងតែរីកចម្រើនខ្លាំង ។ អភិវឌ្ឍន៍វិស័យវិទ្យាសាស្ត្រក្នុងសាសនាបានឈានដល់ថ្នាក់កំពូលនៅឯនគរម៉ាឌីណាស់ គូហ្វាស់ បាក់ដាដ់ ជាពិសេសនៅឯនគរគុំមដែល ចាប់តាំងពីប្អូនស្រីរបស់អ៊ីម៉ាំអារីដ្ហ៍ صلوات الله عليه والسلام បានទទួលអនិច្ចកម្មហើយត្រូវបានបញ្ចុះសពនៅក្នុងនគរនេះ បានក្លាយទៅជាមជ្ឈមណ្ឌលវិទ្យាសាស្ត្រនិងជាទីប្រជុំអ្នកអនុចរតាមគន្លងអាស់លុល–បៃត៍ عليهم السلام ជាពិសេស ។ គេបានឲ្យដឹងថា សិស្សរបស់អ៊ីម៉ាំអ្មាស់ការី صلوات الله عليه والسلام ដែលបានទទួលគុណបុណ្យវិទ្យាសាស្ត្រព្រះអង្គតិចឬច្រើននោះមានចំនួនដល់ ១៨០០០ នាក់ ។

សក្ខីកម្មបញ្ជាក់អំពីវិទ្យាសាស្ត្រ និងគតិបណ្ឌិតខ្ពង់ខ្ពស់របស់អ៊ីម៉ាំ





អះអាងបោកប្រាស់របស់សាសនានានា ។ អល់ឡោះហ៊ូ عزّ وجلّ ទ្រង់ញាណកន្លែងទុកដាក់ព្រះរាជសារព្រះអង្គ عزّ وجلّ ។ បើមិនមានអាស៊្លុល-បៃត៏ទេ عليهم السلام ព្រះរាជសារប្រាកដជាត្រូវកែបំភ្លៃជាមិនខាន មុស្លីមទាំងឡាយនឹងលំអៀងពីព្រះរាជសារនោះដូចបណ្ដាអ្នកកាន់សាសនាឯទៀតដែរ ។

## មេរៀនកែតម្រង់

អ៊ីម៉ាំអាល់-អ៊ាស់ការី صلوات الله عليه والسلام ជាអ្នកបន្តព្រះសន្តវង្សព្រះសាស្ដា صلى الله عليه وآله وسلم ព្រះអយ្យកោ صلى الله عليه وآله وسلم ព្រះអង្គដែលបានហៅមនុស្សទៅកាន់មាគ៌ាល្អដោយសម្ដីល្អ និងឥរិយាបថផ្ទើម ។

ព្រះអង្គចង់បង្ហាត់បង្រៀន វិធីកែតម្រង់នេះឲ្យសាវកទាំងអស់របស់ព្រះអង្គដើម្បីពួកគេនឹងបានទាំងទ្រឹស្ដីស្ថាបនា បានទាំងវិធីសាស្ដ្រប្រាកដប្រជា ។ រឿងរបស់បុរសអ៊ាទ្បារីម្នាក់ ដែលជាកូនចៅរបស់អ៊ីម៉ាំអាស៊្សឹឌិក្ក صلوات الله عليه والسلام ឈ្មោះ អាប៊ូ អាល់-ហ្វាសាន់ ដែលបានភ្ញាក់រលឹកកំហុសនោះ គ្រប់គ្រាន់ណាស់ជាគំរូវិធីសាស្ដ្រដែលអ៊ីម៉ាំអាល់-អ៊ាស់ការី صلوات الله عليه والسلام បានប្រើ ។

បុរសម្នាក់នេះជាប់សាច់ញាតិអ៊ីម៉ាំ ។ គាត់រស់នៅឯស្រុកគុ្ម តែគាត់មិនស័ក្ដិសមនឹងវង្សត្រកូលគាត់ទេ ។ គេស្គាល់គាត់ជាមនុស្សសាងបាបនិងជា



អាល់-អ៊ាស់ការីមានច្រើន ។ តែគេអាចលើកឡើងតែសក្ខីកម្មមួយក៏គ្រប់គ្រាន់ណាស់ហើយ គឺសក្ខីកម្មរបស់ជំនិតរបស់ត្រកូលអ៊ាប់បាស់ម្នាក់ដែលមានឈ្មោះថា មូហ្ម៉ាំម៉ាដ្ឋ ប៊ិន ម៉ាស់អ៊ូដ្ឋ អាស៊្សឹរ៉ាស៊ី (محمود بن مسعود الشيرازى) មនុស្សរបស់ស្ដេចខ៏លិហ្វអាល់-មូអ៊ាតាស៊ុ (المعتز) ។ គាត់បានធ្វើសេចក្ដីរាយការណ៍ថា៖ «តួនាទីវិទ្យាសាស្ដ្ររបស់អ៊ីម៉ាំអាល់-អ៊ាស់ការី صلوات الله عليه والسلام សំខាន់ណាស់ ដល់ថ្នាក់ទស្សនវិទូ អាល់-កាន់ឌី (الكندي) ដែលជាគ្រូរបស់អាល់-ហ្វារ៉ាប៊ី (الفارابي) ត្រូវបង្ខំចិត្តដុតសាត្រាខ្លួនឯងមួយចោលបន្ទាប់ពីត្រូវអ៊ីម៉ាំរិះគន់ ព្រោះព្រះអង្គបានរកឃើញនូវភាពមិនចុះសម្រុងគ្នានៅក្នុងសាត្រានោះ ។»

## ប្រឆាំងពួកបោកប្រាស់

គនរសាម៉ារ៉ាអ៊ុំបានទទួលរងការរាំងស្ងួត ខណៈដែលអ៊ីម៉ាំអាល់-អ៊ាស់ការី صلوات الله عليه والسلام ជាប់ឃុំឃាំង ។ ស្របតាមទំនៀមសាសនាអ៊ីស្លាម សំណាក់មុស្លីមបានចេញទៅខាងក្រៅស្រុក ហើយបានបួងសួងអល់ឡោះហ៊ូ عزّ وجلّ ដើម្បីសូមភ្លៀង តែឥតប្រយោជន៍ ។

ពួកកាន់សាសនាគ្រិស្តក្នុងតំបន់បានប្រជុំគ្នា បានចេញទៅក្រៅស្រុក

ជាមួយមេគណៈសាសនាដើម្បីបួងសួងសូមភ្លៀង ។ ភ្លៀងក៏ចាប់ផ្ដើមធ្លាក់ ធ្វើឲ្យសំណាក់មុស្លីមធ្ងល់ខ្លាំង ។ មុស្លីមមួយចំនួនគិតក្នុងចិត្តថា តើខ្លួនស្ថិតនៅក្នុងសេចក្ដីពិតឬទេ ។ ពួកគេមួយចំនួនចង់ចោលសាសនាខ្លួនទៅកាន់សាសនាគ្រិស្ដវិញ ។

ព្រោះតែខ្លាចអំណាចខ្លួនរង្គោះរង្គើដោយមិនអាចស្មានបាន ស្ដេចខ៏លិហ្វបានចាត់ឲ្យបេសកជនម្នាក់ ទៅជួបអ៊ីម៉ាំអាល់–អ្កាស់ការី صلوات الله عليه والسلام យ៉ាងប្រញាប់ ។ បេសកជនរបស់ស្ដេចខ៏លិហ្វបានទៅជួបអ៊ីម៉ាំក្នុងពន្ធនាគារដោយស្រែកថា៖ «ជួយផង! សហគមន៍របស់ដូនតាព្រះអង្គជួបប្រទះវិនាសអន្ដរាយធំហើយ ។»

អ៊ីម៉ាំអាល់–អ្កាស់ការីបានចេញទៅពិនិត្យមើល ដើមហេតុនៃវិនាសអន្ដរាយនោះ ។ លុះបានទៅដល់ក្រៅស្រុក ព្រះអង្គបានឃើញមានពួកកាន់សាសនាគ្រិស្ដពាក់ពពូនគ្នា អមមេសាសនាពួកគេ ប្រុងបួងសួងសូមទឹកភ្លៀងសាថ្មី ។ អ៊ីម៉ាំបានពិនិត្យមើលទិដ្ឋភាពនេះយ៉ាងយកចិត្តទុកដាក់បំផុត ។ ពេលពួកគ្រិស្ដសាសនិកចាប់ផ្ដើមបួងសួង អ៊ីម៉ាំបានសង្កេតឃើញចៅអធិការម្នាក់លើកដៃឡើង ។ ព្រះអង្គបានបញ្ជាឲ្យបម្រើព្រះអង្គម្នាក់រត់ឆ្ពោះទៅឯ



ចៅអធិការនោះ ទៅយកអ្វីដែលចៅអធិការនេះកាន់ក្នុងដៃស្ដាំ ។ គោរពតាមបញ្ជា គេបានឃើញមានឆ្អឹងខ្មោចមួយដុំ លាក់នៅក្នុងចន្លោះម្រាមដៃចៅអធិការនោះ ។ អ៊ីម៉ាំបានយកឆ្អឹងនោះ ហើយបានប្រាប់ឲ្យពួកគ្រិស្ដសាសនិកបួងសួងសូមទឹកភ្លៀង ។ លើកនេះការបួងសួងរបស់សំណាក់សង្ឃមិនបានលទ្ធផលទេ ថ្វីបើមានមេឃងងឹត ។ ពពកក៏បានរសាត់បាត់អស់ ថ្ងៃលេចមកវិញដើម្បីកម្ចាត់សេចក្ដីសង្ស័យ ដែលកំពុងតែធ្វើឲ្យមុស្លីមកញ្ជ្រោតរាប់ពាន់ច្របូកច្របល់អារម្មណ៍ ។

ស្ដេចខ៏លិហ្វធ្ងល់ បានសួរអ៊ីម៉ាំអំពីអាថ៌កំបាំងរបស់ព្រឹត្តិការណ៍នេះ ។ ព្រះអង្គបានតបថា៖ «ចៅអធិការនេះបានទៅគាស់ផ្នូរព្រះសាស្ដាយកឆ្អឹងពិសិដ្ឋរបស់ព្រះអង្គ ។ ពេលណាឆ្អឹងត្រូវយកចេញមកក្រៅ ពេលនោះមានភ្លៀងធ្លាក់ ។»

នេះគឺគំរូមួយដែលបង្ហាញឲ្យឃើញនូវតួនាទី ដែលប្រកបដោយគុណប្រយោជន៍ ដែលអ៊ីម៉ាំអាល់–អ្កាស់ការី صلوات الله عليه والسلام បំពេញ ។ ហើយនេះក៏ជាសក្ខីភាពរស់រវើកមួយ ដែលសម្ដែងឲ្យឃើញនូវទុព្វលភាពរបស់សំណាក់មុស្លីមដែលឃ្លាតចាកពីខ្សែបន្ទាត់អាស្វលុល–បៃត៍ عليهم السلام បែរទៅរកសេចក្ដី